# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:.....០៤...សសរ....

# សេចក្ដីសំរេច
## ស្ដីពី
## ការបង្កើតលេខាធិការដ្ឋាន គារិយាល័យសន្តិសុខថ្នាក់កណ្ដាល

ꕥꕥꕥ✧ꕥꕥꕥ

### ការិយាល័យសន្តិសុខថ្នាក់កណ្ដាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ
- បានឃើញសេចក្ដីសំរេចលេខ ៥៥ សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២ ស្ដីពីការបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ អាណត្តិទី៣
- ផ្អែកតាមការចាំបាច់របស់ការិយាល័យសន្តិសុខថ្នាក់កណ្ដាល

## សំរេច

ប្រការ ១ : ត្រូវបានបង្កើតលេខាធិការដ្ឋានរបស់ការិយាល័យសន្តិសុខថ្នាក់កណ្ដាល ដែលមានសមាសភាពដូចតទៅ ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្ដម នាយឧត្ដមសេនីយ៍ | ហុក ឡងឌី | អគ្គស្នងការនគរបាលជាតិ | ប្រធាន |
| ២-ឯកឧត្ដម ឧត្ដមសេនីយ៍ | ម៉ុល សារឿន | អគ្គមេបញ្ជាការរង និងជានាយសេនាធិការចំរុះ | អនុប្រធាន |
| ៣-ឯកឧត្ដម | នុត សាអាន | អគ្គលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៤-ឯកឧត្ដម | ជួ កុងឌួន | ទីប្រឹក្សាឯកឧត្ដម ស ខេង | សមាជិក |

| | | | |
|---|---|---|---|
| ៥-ឯកឧត្តម ឧត្តមសេនីយ៍ឯក | ជា តារា | នាយរងសេនាធិការចំរុះ និងជា នាយកទីចាត់ការកលយុទ្ធ | សមាជិក |
| ៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក | ជា សារ៉ន | មេបញ្ជាការរង និងជា នាយសេនាធិការកងទ័ពជើងគោក | សមាជិក |
| ៧-ឯកឧត្តម ឧត្តមសេនីយ៍ឯក | អ៊ុំ សំខាន់ | មេបញ្ជាការកងទ័ពជើងទឹក | សមាជិក |
| ៨-ឯកឧត្តម ឧត្តមសេនីយ៍ឯក | ស៊ឹម សំណាង | មេបញ្ជាការកងទ័ពជើងអាកាស | សមាជិក |
| ៩-ឯកឧត្តម ឧត្តមសេនីយ៍ឯក | សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថ លើផ្ទៃប្រទេស | សមាជិក |
| ១០-ឯកឧត្តម ឧត្តមសេនីយ៍ទោ | យូ ស៊ុនឡុង | ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ | សមាជិក |
| ១១-ឯកឧត្តម ឧត្តមសេនីយ៍ទោ | នេត សាវឿន | ប្រធាននាយកដ្ឋានកណ្តាល នគរបាលយុត្តិធម៌ | សមាជិក |
| ១២-ឯកឧត្តម ឧត្តមសេនីយ៍ទោ | ម៉ៅ ច័ន្ទតារា | ប្រធានសេនាធិការ អគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ | សុខ ផល | ប្រធាននាយកដ្ឋានព័ត៌មានទូទៅ | សមាជិក |
| ១៤-ឯកឧត្តម ឧត្តមសេនីយ៍ទោ | ខៀវ សុគន្ធ | អគ្គលេខាធិការរង ក្រសួងមហាផ្ទៃ | សមាជិក |
| ១៥-លោកឧត្តមសេនីយ៍ត្រី | គន្ធ សំអឿន | ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម | សមាជិក |
| ១៦-លោកឧត្តមសេនីយ៍ត្រី | ថាន គឹមហោ | ប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ | សមាជិក |
| ១៧-លោកឧត្តមសេនីយ៍ត្រី | វ៉ាន់ វណ្ណា | ប្រធាននាយកដ្ឋាននគរបាល បច្ចេកទេស វិទ្យាសាស្ត្រ | សមាជិក |
| ១៨-លោក | ម៉ម ប៊ុន | អនុប្រធាននាយកដ្ឋានថវិកានីយកម្មនិង ហិរញ្ញកិច្ច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |

ប្រការ ២ : លេខាធិការដ្ឋានមានភារកិច្ច :

- ជួយប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល ក្នុងការផ្សព្វផ្សាយ និងតាមដានចាត់តាំងអនុវត្ត ផែនការការពារសន្តិសុខសុវត្ថិភាពក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ ។
- ផ្សព្វផ្សាយគោលការណ៍ ផែនការផ្សេងៗ របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ជូនទៅការិ-យាល័យសន្តិសុខថ្នាក់ក្រោម ។
- ចាត់តាំងកំលាំងដើម្បីប្រតិបត្តិការការពារការបោះឆ្នោត តាមគំរោងផែនការដែលបានកំណត់ ។
- ប្រមូលផ្តុំព័ត៌មានពីការិយាល័យសន្តិសុខថ្នាក់ក្រោម ដើម្បីរាយការណ៍ជូនប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល ។
- ពិនិត្យដោះស្រាយរាល់វិវាទផ្សេងៗ ឬបណ្តឹងតវ៉ា ពាក់ព័ន្ធដល់សន្តិសុខនៃការបោះឆ្នោត ធ្វើរបាយការណ៍ជូនការិយាល័យសន្តិសុខថ្នាក់កណ្តាល រៀងរាល់ ១៥ថ្ងៃម្តង ។
- រៀបចំកម្មវិធីប្រជុំ ធ្វើលិខិតអញ្ជើញគ្រប់សមាជិកការិយាល័យសន្តិសុខថ្នាក់កណ្តាលទាំងអស់ និងគ្រប់គ្រងឯកសារនានា តាមការសំរេចរបស់ប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល ។
- ធ្វើគំរោងថវិកា ឧបករណ៍ សំភារៈ មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ សំរាប់បំរើការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដាក់ជូនប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាលពិនិត្យ និងសំរេច ។

4k

- ប្រមូលផ្តុំចាត់ចែងប្រើប្រាស់សំភារៈ ឧបករណ៍ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ របស់បណ្តាអង្គភាពផ្ទាល់ដែលមានស្រាប់ ដើម្បីបំរើដល់ប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់អោយបានល្អប្រសើរ ក្នុងរយៈពេលដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- ចាត់ចែងបើកផ្តល់ថវិកាបំប៉នជូនកំលាំងការពារតាមគោលដៅ និងចាត់ចែងធ្វើគំរោងបែងចែកឧបករណ៍ សំភារៈ មធ្យោបាយដឹកជញ្ជូន អោយបានសមស្របតាមមុខសញ្ញា និងគោលដៅចាំបាច់ ។
- ធ្វើរបាយការណ៍ចំណូល ចំណាយថវិកា និងការប្រើប្រាស់ឧបករណ៍ សំភារៈ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទប្រចាំខែ ជូនការិយាល័យសន្តិសុខថ្នាក់កណ្តាល ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល ។
- ចាត់ចែងធ្វើការផ្សព្វផ្សាយនៅក្នុង និងទៅក្រៅប្រទេស នូវពត៌មានទាំងឡាយណា ដែលពិនិត្យឃើញថា ចាំបាច់ត្រូវជូនដល់សាធារណមតិជាតិ និងអន្តរជាតិបានជ្រាបផង ។

<u>ប្រការ ៣</u> : ក្នុងករណីចាំបាច់ លេខាធិការដ្ឋានអាចស្នើសុំការិយាល័យសន្តិសុខថ្នាក់កណ្តាល អោយបង្កើតក្រុមការងារជំនាញនានា ដើម្បីជាជំនួយការក្នុងការតាមដាន ដឹកនាំ បញ្ជា ឬកិច្ចការរដ្ឋបាល ។

លេខាធិការដ្ឋានការិយាល័យសន្តិសុខថ្នាក់កណ្តាលមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

<u>ប្រការ ៤</u> : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០០៣*

*ឧបនាយករដ្ឋមន្ត្រី*
*និងជាប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល*

*ស ខេង*

<u>ចំលងជូន</u> :
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងមហាផ្ទៃ*
- *ក្រសួងការពារជាតិ*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
- *អគ្គមេបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ*
- *បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស*
- *គ្រប់សាលាខេត្ត ក្រុង*
- *ដូចក្នុងប្រការ១*
- *ឯកសារ-កាលប្បវត្តិ*